## Making suggestions in which the speaker is included



នៅក្នុងសួនកម្សាន្ត
ផារី៖ វិចិត្រ ខ្ញុំដូចជាឃ្លានហើយនៀក តស់ ទៅរកញ៉ាំអីសិនអេ៎?
វិចិត្រ៖ តស់ទៅ! ខ្ញុំក៏ឃ្លានដែរ ហើយហត់ទៀត។ ដើរម៉ាព្រឹកហើយ!
ផារី៖ វិចិត្រ ចង់ញ៉ាំអី?
វិចិត្រ៖ អីក៏បានដែរ។ នៅមុខនោះមានគេលក់មីឆា។ ញ៉ាំមីឆាម៉ងទៅ ម៉េចដែរ?
ផារី៖ មានអី តស់ទៅ។

ជិះរថយន្តតាមផ្លូវ
វិចិត្រ៖ ពេលដល់ហ្គារ៉ាស់សាំងមុខហ្នឹង ខ្ញុំសុំចូលចាក់សាំងតិចសិនណា។
ផារី៖ មានអី។ ស្តុបខាងមុខ ហ្នឹងមែន?
វិចិត្រ៖ ហ្នឹងហើយ។ ចូលតាម៉ាភ្លែតអេ៎។

ជិះម៉ូតូតាមផ្លូវ
ផារី៖ វិចិត្រ ឆ្លៀតចូលផ្សារទិញអីវ៉ាន់តិចអី?
វិចិត្រ៖ ចង់ចូលឥឡូវហ្នឹង? យប់ហើយហ្នឹង។ ចាំលើកក្រោយទៅអី?
ផារី៖ ចូលតិចទៅអី។
វិចិត្រ៖ អីចឹង ផារីឯងចូលទៅ ខ្ញុំនៅចាំនៅក្រៅ។ ខ្ជិលផ្ញើម៉ូតូ។
ផារី៖ មិនបាច់អេ៎អីចឹង។ នាំពិបាកវិចិត្រឯង។

| | |
|---|---|
| សួនកម្សាន្ត | park, amusement park |
| ផារី / វិចិត្រ | female / male Cambodian names |
| នៀក | spoken form of នេះ |
| តស់ | Let's go! |
| សិន | first, now |
| ហត់ | tired |
| ដើរម៉ាព្រឹកហើយ | we've been walking [around] all morning; ម៉ា is the spoken form of មួយ |
| អីក៏បានដែរ | anything is fine |
| ម៉ងទៅ = តែម្តងទៅ | just (as in: let's just have fried noodles) |
| ម៉េចដែរ? | What do you think? / How's that? |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| មានអី | ok |
| ហ្គារ៉ាស់សាំង | petrol station |
| ចាក់សាំង | to fill up petrol |
| ស្តុប | traffic light |
| តាម៉ាភ្លែតអេ៎! | spoken form of តែមួយភ្លែតទេ! = just a moment! |
| ឆ្លៀត | to make good use of time, to take the time to do something |
| ... តិចអី? | used to ask for agreement to a suggestion |
| ចាំលើកក្រោយទៅអី? | Can['t] this wait until next time? / Can we do this next time? |
| ខ្ជិលផ្ញើម៉ូតូ | [I] don't want to park the motorbike (paid parking) |
| នាំពិបាក | to be (or to result in being) bothersome/tedious/tiresome |

## Cultural notes

នៅពេលកំពុងដើរឬធ្វើការងារអ្វីមួយជាមួយមិត្តភក្តិ ហើយអ្នកចង់ទិញអ្វីមួយញ៉ាំ អ្នកក៏ត្រូវបបួលឬទិញចំណែកសម្រាប់មិត្តភក្តិរបស់អ្នកផងដែរ ទើបជាការគួរសម។ នេះប្រហែលជារឿងធម្មតាសម្រាប់វប្បធម៌នៅប្រទេសផ្សេងទៀតផងដែរ មិនមែនតែនៅខ្មែរនោះទេ។

| | |
|---|---|
| បបួល | to invite |
| ការគួរសម | politeness |
| វប្បធម៌ | culture |

## Additional dialogue

នៅសួនកម្សាន្ត

វិចិត្រ៖ ផារី តស់ទៅញ៉ាំអីសិន ខ្ញុំឃ្លានហើយ។ នៅមុខនោះមានហាងលក់ភីហ្សាមួយ។
ផារី៖ វិចិត្រឃ្លានហើយអ៎? ខ្ញុំដូចជាអត់ទាន់ឃ្លានផង តែស្រេកទឹក។ វិចិត្រទៅហាងនុងមុនទៅ។ ខ្ញុំទៅទិញទឹកកកឈូសនៅនោះសិន ហើយចាំជុំគ្នាវិញនៅហាងភីហ្សានុងម៉ង។
វិចិត្រ៖ អីចឹងក៏បាន។ ចង់ឲ្យខ្ញុំកុម្ម៉ង់អីញ៉ាំឲ្យហើយអត់?
ផារី៖ មិនបាច់ទេ។ ចាំខ្ញុំទៅដល់ ខ្ញុំកុម្ម៉ង់ខ្លួនឯងក៏បាន។

| | |
|---|---|
| ភីហ្សា | pizza |
| ស្រេកទឹក | to be thirsty |
| នុង | spoken form of នោះ |
| ទឹកកកឈូស | shaved ice |
| កុម្ម៉ង់ | to order (food) |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.